ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការបញ្ជូនត្រឡប់មកកម្ពុជាវិញនូវវត្ថុបុរាណខ្មែរចំនួន២០រូប ពីអ្នកកាន់កាប់សមុច្ច័យឯកជនមួយនៅតំបន់អាស៊ី

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនជ្រាបថា វត្ថុបុរាណខ្មែរចំនួន២០រូប ដែលទាមទារបានពីអ្នកកាន់កាប់សមុច្ច័យឯកជនមួយនៅតំបន់អាស៊ី ត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញដោយជោគជ័យ។ ការប្រគល់មកវិញនៃវត្ថុទាំងនេះ គឺជាសមិទ្ធផលដ៏ធំធេងថ្មីមួយទៀត តាមរយៈកិច្ចខិតខំប្រឹងប្រែងជាប្រចាំរបស់កម្ពុជា ក្នុងការទាមទារ និងស្តារឡើងវិញនូវមរតកវប្បធម៌ជូនតាសម្រាប់កូនចៅជំនាន់ក្រោយ។

សមុច្ច័យដែលបានប្រគល់មកវិញមានលក្ខណៈចម្រុះ សាងពីថ្មភក់ និងសំរិទ្ធ ដូចជា រូបបដិមាសម័យបាយ័ន ដែលគេជឿថាមានប្រភពដើមមកពីក្រុងអង្គរធំ។ សម្បត្តិវប្បធម៌ទាំងនេះមិនត្រឹមតែជាវត្ថុសិល្បៈទេ តែជាសាក្សីរស់នៃបញ្ញាញាណរបស់បុព្វបុរស និងដួងព្រលឹងនៃអរិយធម៌ខ្មែរ ដែលនឹងផ្តល់ការយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជា។

ដំណើរការទាមទារនេះអាចសម្រេចទៅបាន ដោយមានការចូលរួមជ្រោមជ្រែងពីអ្នកជំនាញនៃក្រុមការងារស្រាវជ្រាវ ដែលបានផ្តល់ប្រឹក្សា និងរៀបចំការចរចា រហូតឈានដល់ការប្រគល់វត្ថុទាំងនេះមកកម្ពុជាវិញ។ បុគ្គលស្នូលក្នុងកិច្ចការនេះ គឺលោក Imran Hamid Khwaja ជាដៃគូនៃក្រុមហ៊ុន Tan Rajah & Cheah ដែលជាក្រុមហ៊ុនច្បាប់ដ៏ចំណាស់បំផុតមួយរបស់ប្រទេសសិង្ហបុរី និងជាមេធាវីដែលមានបទពិសោធន៍ទូលំទូលាយក្នុងការដោះស្រាយវិវាទអន្តរជាតិ។ លោក Khwaja និងលោក Bradley J. Gordon នៃក្រុមហ៊ុន Edenbridge Asia បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសហការ និងចរចាបញ្ជូនត្រឡប់មកវិញនៃរតនវត្ថុជាតិទាំងនេះ។

ការប្រគល់មកវិញនូវវត្ថុបុរាណទាំងនេះ សបញ្ជាក់យ៉ាងច្បាស់ពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការបន្តស្វែងរកយុត្តិធម៌ សម្រាប់បេតិកភណ្ឌវប្បធម៌របស់ខ្លួន។ កម្ពុជាមានក្តីរំភើបចំពោះការវិលត្រឡប់មកវិញនៃព្រលឹងដូនតាខ្មែរមកកាន់មាតុភូមិកំណើត។ សមិទ្ធផលនេះ បានបញ្ជូនសារយ៉ាងច្បាស់ថា ប្រជាជនកម្ពុជាបន្តរួបរួមគ្នាជាធ្លុងមួយក្នុងការការពារមរតកវប្បធម៌របស់ខ្លួនសម្រាប់មនុស្សជាតិទាំងមូល។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រី និង សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងនយោបាយឈ្នះ-ឈ្នះ ដែលបាននាំមកនូវសុខសន្តិភាពពេញលេញ និងស្ថិរភាព ដែលបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ការស្វែងរក និងទាមទារមកវិញនូវសម្បត្តិវប្បធម៌ខ្មែរ ដែលបានបាត់បង់ក្នុងសម័យសង្គ្រាម និងអសន្តិសុខក្នុងប្រទេស។

ក្រសួងសូមថ្លែងអំណរគុណដល់ដៃគូអន្តរជាតិ និងក្រុមការងារ ដែលបានសម្របសម្រួលក្នុងការងារនេះ រួមមាន៖ ក្រុមការងារស្រាវជ្រាវរបស់ក្រសួង, លោក Bradley J. Gordon (Edenbridge Asia) និងជាទីប្រឹក្សាផ្នែកច្បាប់

របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, កញ្ញា Melina Antoniadis (NOSTOS Strategies) និងលោក Imran Hamid Khwaja (Tan Rajah & Cheah) ។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈសូមអំពាវនាវនិងលើកទឹកចិត្តដល់សារមន្ទីរ និងអ្នកប្រមូលសមុច្ច័យឯកជននានា ដែលកំពុងកាន់កាប់វត្ថុបុរាណខ្មែរ សូមទាក់ទងមកក្រសួង និងចូលរួមពិភាក្សាប្រកបដោយវិជ្ជាជីវៈ ក្នុងការប្រគល់វត្ថុបុរាណខ្មែរមកកម្ពុជាវិញ។

ថ្ងៃចន្ទ ៤រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៦

| រូបថត - Photograph | ពិពណ៌នា Description |
| --- | --- |
|  | **ព្រះសិរ្សទេវតា**<br>ថ្មភក់<br>សម័យអង្គរ, រចនាបថបាយ័ន្ត ចុងស.វ.ទី១២-ដើម១៣ គ.ស.<br>៩១ x ៤៨ ស.ម.<br><br>**Head of Devata**<br>Sandstone<br>Angkor period, Bayon style, late12th-early 13th C.<br>91 x 48 cm. |
|  | **ព្រះសិរ្សអសុរ**<br>ថ្មភក់<br>សម័យអង្គរ, រចនាបថបាយ័ន្ត ចុងស.វ.ទី១២-ដើម១៣ គ.ស.<br>៧៨ x ៤៦ x ៥១.៥ ស.ម.<br><br>**Head of Asura/Demon**<br>Sandstone<br>Angkor period, Bayon style, late12th-early 13th C. |
|  | **ព្រះសិរ្សទេវតា**<br>ថ្មភក់<br>សម័យអង្គរ, រចនាបថបាយ័ន្ត ចុងស.វ.ទី១២-ដើម១៣ គ.ស.<br>៥០ x ៤៤ x ៣៤ ស.ម.<br><br>**Head of Devata**<br>Sandstone<br>Angkor period, Bayon style, late 12th-early 13th C.<br>50 x 44 x 34 cm. |

| | |
|---|---|
|  | ទេពប្រុស<br>សំរឹទ្ធ<br>សម័យអង្គរ ស.វ.ទី១២ គ.ស.<br>៧.២ x ២.៨ x ២ ស.ម<br><br>**Male Deity**<br>Bronze<br>Angkor period, 12th C.<br>7.2 x 2.8 x 2 cm. |
|  | ព្រះនារាយណ៍<br>ថ្មភក់<br>សម័យអង្គរ ស.វ.ទី១១ គ.ស.<br>៧១ x ៣៨ x ១៩ ស.ម.<br><br>**Vishnu**<br>Sandstone<br>Angkor period, 11th C.<br>88 x 38 x 19 cm. |
|  | ព្រះនារាយណ៍<br>ថ្មភក់<br>សម័យអង្គរ ស.វ.ទី១១-១២ គ.ស.<br>៦៦ x ៣៣ x ៩ ស.ម.<br><br>**Vishnu**<br>Sandstone<br>Angkor period, 11th-12th C.<br>66 x 33 x 9 cm. |